ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៥៩ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្ដីពី
# ការកំណត់ថ្លៃឈ្នួលផ្ទេរក្រឡាប្លុកប្រេងកាត

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

### ប្រការ១ .-

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត ត្រូវបង់ថ្លៃឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត ស្របតាមការកំណត់ក្នុងប្រកាសអន្តរក្រសួងនេះ។

### ប្រការ២ .-

ថ្លៃឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត ត្រូវកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | ថ្លៃឈ្នួលប្រចាំឆ្នាំ/គីឡូម៉ែត្រការ៉េ |
|---|---|---|
| ១ | ឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត សម្រាប់ដំណាក់កាលស្វែងរុករកទី១ និងការពន្យារពេលបន្ថែម | ១៥ (ដប់ប្រាំ) ដុល្លារអាម៉េរិក |
| ២ | ឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត សម្រាប់ដំណាក់កាលស្វែងរុករកទី២ និងការពន្យារពេលបន្ថែម | ៣០ (សាមសិប) ដុល្លារអាម៉េរិក |
| ៣ | ឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត សម្រាប់ដំណាក់កាលស្វែងរុករកទី៣ | ៤៥ (សែសិបប្រាំ) ដុល្លារអាម៉េរិក |
| ៤ | ឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត លើសពីដំណាក់កាលស្វែងរុករកទី៣ | ៦០ (ហុកសិប) ដុល្លារអាម៉េរិក |

| | | |
|---|---|---|
| ៥ | ឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត សម្រាប់ការរក្សាទុកតំបន់មានឧស្ម័ន | ១០០ (មួយរយ) ដុល្លារអាមេរិក |
| ៦ | ឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត សម្រាប់ផលិតកម្មប្រេងកាត | ៥០០ (ប្រាំរយ) ដុល្លារអាមេរិក |

**ប្រការ៣ .-**

អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត ត្រូវបង់ថ្លៃឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាតតាមកាលបរិច្ឆេទ ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងប្រេងកាត និងត្រូវបង់ចូលគណនីចរន្តនៅធនាគារពាណិជ្ជដៃគូ ដែលមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីអ្នកចុះកិច្ចព្រមព្រៀងប្រេងកាត ខកខានមិនបានបង់ថ្លៃឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត ស្របតាមការកំណត់ក្នុងប្រកាសអន្តរក្រសួងនេះ អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត ត្រូវទទួលរងនូវការផាកពិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៤ .-**

ក្នុងករណីកិច្ចព្រមព្រៀងប្រេងកាតត្រូវបានបញ្ចប់មុនកាលកំណត់ ថ្លៃឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាត ដែលបានបង់រួច ត្រូវចាត់ទុកជាគុណប្រយោជន៍ថវិការដ្ឋ។

**ប្រការ៥ .-**

ក្រសួងរ៉ែ និងថាមពល ត្រូវធ្វើរបាយការណ៍ស្តីពីការប្រមូលចំណូលថ្លៃឈ្នួលផ្ទៃក្រឡាប្លុកប្រេងកាតប្រចាំត្រីមាស ឆមាស និងឆ្នាំ រួចផ្ញើជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦ .-**

ត្រូវបាននិរាករណ៍ប្រកាសរួម និងប្រកាសអន្តរក្រសួង ដូចខាងក្រោម៖

- ប្រកាសរួមលេខ១៤៥១ សហវ.ប្រក ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- ប្រកាសអន្តរក្រសួងលេខ១២៨ សហវ.ប្រក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១ សហវ.ប្រក ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៧រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កែវ រតនៈ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ